ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
ខុទ្ទកាល័យ
ចូល
លេខ 1700
ថ្ងៃទី 16-5-2014 ម៉ោង 15
បញ្ជូន

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៨០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតអគ្គនាយកដ្ឋានលំនៅឋាន ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១ ៖** ត្រូវបានបង្កើតអគ្គនាយកដ្ឋានលំនៅឋាន ចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

**មាត្រា ២ ៖** អគ្គនាយកដ្ឋានលំនៅឋានមានតួនាទីជាសេនាធិការជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការសិក្សាអំពីស្ថានភាព តម្រូវការនិងការផ្គត់ផ្គង់លំនៅឋាន, ការរៀបចំយុទ្ធសាស្ត្រ គោលនយោបាយ និងបទដ្ឋានគតិយុត្ត, សហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍ សង្គមស៊ីវិល វិស័យឯកជន សប្បុរសជន និងកៀរគរហិរញ្ញប្បទានសម្រាប់ការងារលំនៅឋាន និងរៀបចំមូលនិធិនិងឥណទានលំនៅឋាន។

**មាត្រា ៣ ៖** អគ្គនាយកដ្ឋានលំនៅឋាន ដឹកនាំដោយអគ្គនាយក ០១ រូប និងមានអគ្គនាយករងមួយចំនួនជាជំនួយការតាមការចាំបាច់។

**មាត្រា ៤ ៖** អគ្គនាយកដ្ឋានលំនៅឋាន មាននាយកដ្ឋានចំណុះចំនួន ៣ គឺ:

១- នាយកដ្ឋានបទប្បញ្ញត្តិ ផែនការនិងទំនាក់ទំនងសហប្រតិបត្តិការការងារលំនៅឋាន

២- នាយកដ្ឋានបច្ចេកទេស និងអភិវឌ្ឍលំនៅឋាន

៣- នាយកដ្ឋានមូលនិធិនិងឥណទានលំនៅឋាន

**មាត្រា ៥ ៖** តួនាទី ភារកិច្ចរបស់អគ្គនាយកដ្ឋានលំនៅឋាន និងតួនាទីរបស់នាយកដ្ឋានចំណុះត្រូវកំណត់ដោយអនុក្រឹត្យមួយដោយឡែក។

**មាត្រា ៦ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៧ ៖** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈរដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ១០ ឆ្នាំ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

**សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**អ៊ឹម ឈុនលឹម**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# អង្គការលេខរបស់អគ្គនាយកដ្ឋានលំនៅឋាន

**អគ្គនាយកនៃអគ្គនាយកដ្ឋានលំនៅឋាន**
ឯកឧត្តម **ប្រាក់ អង្គារ៉ា** 012 869 377

**អគ្គនាយករង**
១. លោក **ហ៊ី ចិន្តា** 012 882 498
២. លោក **ដោក ដូម៉ា** 012 725 669
៣. លោក **ទេព កោសល្យ** 012 873 314
៤. លោក **ភួន ភូម៉ូនីរតន៍** 011 611 611

## នាយកដ្ឋានបទប្បញ្ញត្តិ ផែនការ និងទំនាក់ទំនងសហប្រតិបត្តិការការងារលំនៅឋាន
លោក **លី ចាន់ ភក្តី** 077 277 279

**អនុប្រធាននាយកដ្ឋាន**
១. លោក **ង៉ូវ សំណាង** 017 517 673
២. កញ្ញា **វង្ស និមល** 012 627 045
៣. លោក **នួន ប៉ុក** 076 668 1618
៤. លោក **យូលីន សីរីវ័ត្ន** 012 666 201
៥. លោក **ផ្ទង លីជីហ៊ុន** 069 609 969

**ការិយាល័យទំនាក់ទំនងសាធារណៈ និងកិច្ចការទូទៅ**
លោក **ចេង ជឿង** 012 990 096

**ការិយាល័យផែនការ**
លោក **កែវ មុនី** 011 645 439

**ការិយាល័យបទប្បញ្ញត្តិ**
លោក **រាម កេរ្តិ៍សុវណ្ណ** 086 966 244

**ការិយាល័យសហប្រតិបត្តិការជាតិ និងអន្តរជាតិ**
លោក **ឡា វេហា** 077 718 466

## នាយកដ្ឋានបច្ចេកទេស និងអភិវឌ្ឍលំនៅឋាន
លោក **សុខ សំអុន** 017 542 333

**អនុប្រធាននាយកដ្ឋាន**
១. លោក **ទេព ផៃតពិសិដ្ឋ** 077 753 333
២. លោក **ប្រាក់ និមល** 088 897 777
៣. លោក **គឹម បូរ៉ាស៊ី** 012 825 455
៤. លោក **ម៉ៅ ច័ន្ទរស្មី** 017 535 337
៥. លោក **ទន ជិនហេង** 017 888 485

**ការិយាល័យគ្រប់គ្រងឯកសារ និងរៀបចំផែនការ**
លោក **សម្បត្តិ មុនីឧត្តម** 092 234 582

**ការិយាល័យសិក្សាគម្រោងអភិវឌ្ឍលំនៅឋាន**
លោក **នី វណ្ណៈ** 012 995 544

**ការិយាល័យកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងលំនៅឋាន**
លោកស្រី **តាំង សុបញ្ញា** 012 839 546

**ការិយាល័យសិក្សាស្រាវជ្រាវ និងបណ្តុះបណ្តាលបទដ្ឋានបច្ចេកទេសលំនៅឋាន**
លោក **អ៊ុន សុវណ្ណារ៉ា** 011 721 272

## នាយកដ្ឋានមូលនិធិ និងឥណទានលំនៅឋាន
លោកស្រី **លី តារា** 011 770 183

**អនុប្រធាននាយកដ្ឋាន**
១. លោក **កែង សុវណ្ណារ៉ាន់** 017900 873
២. លោកស្រី **អ៊ុក ដានែត** 012250715
៣. លោកស្រី **ជ្រិន ណៃ** 012895529
៤. លោក **សួរ ណារ៉ូ** 012 485 878
៥. លោក **ឆើ សំបុល** 012 303 335

**ការិយាល័យស្រាវជ្រាវទីផ្សារ សេវាហិរញ្ញវត្ថុ**
លោក **ពិន សុវណ្ណារិទ្ធ** 011 717 986

**ការិយាល័យមូលនិធិ និងឥណទានលំនៅឋាន**
លោកស្រី **ប៉ែន មុន្នីរ័ត្ន** 016 958 859

**ការិយាល័យកំណត់លក្ខណវិនិច្ឆ័យ និងគ្រប់គ្រងលំនៅឋាន**
លោកស្រី **វន សុខហេង** 012 418 439

**ការិយាផែនការថវិកា**
លោក **ទឹម ភីយ៉ារ៉ូ** 015 252 629

## នាយកដ្ឋានសម្បទានដីសង្គមកិច្ច
លោក **ឫទ្ធី រតនៈជ័យសិទ្ធិ** 017 998 333

**អនុប្រធាននាយកដ្ឋាន**
១. លោក **ស៊ិន សុខុន** 017 440 016
២. លោក **សែង សង** 012 544 407
៣. លោកស្រី **កាយ សុធារី** 012 266 150
៤. លោក **តួច ឫទ្ធិត្យា** 012 928 209

**ការិយាល័យគាំទ្របច្ចេកទេសសម្បទានដីសង្គមកិច្ច**
កញ្ញា **នួន មន្ថា** 012 971 316

**ការិយាល័យមុខសញ្ញាអ្នកទទួលដីសម្បទានសង្គមកិច្ច**
លោកស្រី **សុខ សែនភិរម្យ** 016 821 128

**ការិយាល័យផែនការនិងគាំទ្រការអភិវឌ្ឍកម្មវិធីសម្បទានដីសង្គមកិច្ច**
លោក **រស់ រក្សា** 017 876 598

**ការិយាល័យកិច្ចការទូទៅនិងត្រួតពិនិត្យកិច្ចការសម្បទានសង្គមកិច្ច**
កញ្ញា **ហេង រង្សី** 012 653 763